**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ: ៥៧១ សជណ

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦

## សូមជម្រាបជូន

### ឯកឧត្តម អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត

**កម្មវត្ថុ** : ស្តីពីការរៀបចំបញ្ជីបច្ចុប្បន្នភាពស្មៀនឃុំ សង្កាត់ នៅទូទាំងប្រទេស ។

**យោង** : ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន**ឯកឧត្តម**មេត្តាជ្រាបថា កន្លងមក ក្រសួងមហាផ្ទៃបានពិនិត្យឃើញថា ស្មៀនឃុំ សង្កាត់មួយចំនួនបានចូលនិវត្តន៍ ទទួលមរណភាព និងមួយចំនួនត្រូវបានតែងតាំងមុខតំណែង ឬផ្លាស់ប្តូរភារកិច្ចទៅបម្រើការងារនៅតាមសាលាក្រុង ស្រុក ខណ្ឌ។ ពាក់ព័ន្ធនឹងបញ្ហានេះ រាជធានី ខេត្តមួយចំនួនបានយកចិត្តទុកដាក់លើកសំណើមកក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ សម្រេចចេញប្រកាសតែងតាំង និងផ្លាស់ប្តូរស្មៀនឃុំ សង្កាត់ស្របតាមការកំណត់។ ទន្ទឹមនោះ ក៏មានស្មៀនឃុំ សង្កាត់មួយចំនួនទៀតត្រូវបានតែងតាំង ឬប្រគល់ភារកិច្ចជាបណ្តោះអាសន្នដោយដីកា ឬសេចក្តីសម្រេច ឬលិខិតបង្គាប់ការរបស់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលពុំទាន់បានអនុវត្តឲ្យមានលក្ខណៈត្រឹមត្រូវតាមគោលការណ៍ បែបបទ និងនីតិវិធី ដែលបានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនៅឡើយ។

ពាក់ព័ន្ធនឹងបញ្ហាខាងលើនេះ ក្រសួងស្នើរដ្ឋបាលរាជធានី ខេត្តនីមួយៗ យកចិត្តទុកដាក់ពិនិត្យណែនាំ និងចាត់ចែងលើកសំណើសុំតែងតាំង ឬផ្លាស់ប្តូរស្មៀនឃុំ សង្កាត់ដែលនៅទំនេរ ឬដែលមិនទាន់បានបំពេញបែបបទស្របតាមគោលការណ៍ បែបបទ និងនីតិវិធីកំណត់។ ក្នុងករណីខ្វះខាតមន្ត្រីរាជការដើម្បីស្នើតែងតាំងជាស្មៀនឃុំ សង្កាត់នោះ រាជធានី ខេត្តនីមួយៗ ត្រូវរាយការណ៍ជាបន្ទាន់មកក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ សម្រេច។

ដើម្បីធានានូវប្រសិទ្ធភាព និងការគ្រប់គ្រងស្ថានភាពមន្ត្រីស្មៀនឃុំ សង្កាត់ទាំងអស់ ឲ្យមានលក្ខណៈពិតប្រាកដ ជាក់ស្តែង និងមានស្មៀនឃុំ សង្កាត់បំពេញតួនាទី ភារកិច្ចស្របតាមសំណូមពរការងារនាពេលបច្ចុប្បន្ន ក្រសួងមហាផ្ទៃស្នើឯកឧត្តមអភិបាលរាជធានី ខេត្ត ចាត់ឲ្យរៀបចំធ្វើបញ្ជីបច្ចុប្បន្នភាពស្មៀនតាមរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមតារាងបញ្ជីឈ្មោះដូចមានជូនភ្ជាប់មកជាមួយ រួចផ្ញើ ( ជាHard និងSoftCopy) មកក្រសួងមហាផ្ទៃ (នាយកដ្ឋានបុគ្គលិកនៃអគ្គនាយកដ្ឋានរដ្ឋបាល) ឬតាមរយៈអ៊ីម៉ែល sokvisothea@ymail.com ឬ virak_toch2009@yahoo.com ឲ្យបានមុនយ៉ាងយូរត្រឹម**ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៦** ជាកំហិត។

អាស្រ័យហេតុនេះ សូម**ឯកឧត្តម** ជ្រាប និងចាត់ចែងអនុវត្តឲ្យមានប្រសិទ្ធភាព ។

សូម**ឯកឧត្តម** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

**ជ. រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**សខ ភក្តា**

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- លេខាធិការដ្ឋាន គ.ជ.អ.ប

"ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ